# អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
# និយ័តករគណនេយ្យនិងសវនកម្ម

## សៀវភៅណែនាំអំពីការប្រើប្រាស់ប្រព័ន្ធ
## គ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស

## e-Filing User Guide

*រក្សាសិទ្ធិគ្រប់យ៉ាងដោយនិយ័តករគណនេយ្យនិងសវនកម្ម*

# មាតិកា


ដ្យាក្រាម ........................................................................ ៣

អក្សរកាត់ ........................................................................ ៥

ពាក្យបច្ចេកទេស ................................................................ ៥

១.សេចក្តីផ្តើម .................................................................... ៦

២.គោលបំណង ...................................................................... ៧

៣.អំពីប្រព័ន្ធ ........................................................................ ៨

....... ៣.១.ទិដ្ឋភាពរួម ............................................................. ៨

....... ៣.២.នីតិវិធីអនុវត្ត ........................................................ ៨

៤.លំហូរការងារ និងរបៀបអនុវត្ត ............................................ ១០

....... ៤.១.ការគ្រប់គ្រងគណនី ................................................... ១០

....... ៤.២.ការដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណកម្ម ........................ ១៦

....... ៤.៣.ការដាក់របាយការណ៍ហិរញ្ញវត្ថុ ..................................... ២៣

# ដ្យាក្រាម


*Figure 1: Overview of e-Filing System* ..... ៧

*Figure 2: Overview of Requesting FIN Module* ..... ៨

*Figure 3: Overview of Submitting FS Module* ..... ៩

*Figure 4: ACAR Website* ..... ១០

*Figure 5:Authentication Page* ..... ១០

*Figure 6:Create Account Form* ..... ១១

*Figure 7:Resend Email Form* ..... ១១

*Figure 8:Set Password Email* ..... ១២

*Figure 9:Set Password Form* ..... ១២

*Figure 10: Log in Form* ..... ១៣

*Figure 11: Reset Password Link* ..... ១៣

*Figure 12: Reset Email Form* ..... ១៤

*Figure 13: Reset Password Email* ..... ១៤

*Figure 14: Reset Password Form* ..... ១៥

*Figure 15: e-Filing System Dashboard – Requesting FIN Module* ..... ១៦

*Figure 16: Requesting FIN – Choosing Entity Type* ..... ១៦

*Figure 17: Requesting FIN – General Information Form* ..... ១៧

*Figure 18: Requesting FIN – Address Information Form* ..... ១៧

*Figure 19: Requesting FIN – Financial Information Form* ..... ១៨

*Figure 20: Requesting FIN – Audit Information Form* ..... ១៨

*Figure 21: Requesting FIN – Uploading Documents Form* ..... ១៩

*Figure 22: Requesting FIN – Confirm Information Form* ..... ១៩

*Figure 23: Requesting FIN – Submit Form* ........ ២០

*Figure 24: Requesting FIN – Pending Appoval Form* ........ ២១

*Figure 25: e-Filing System Dashboard – FIN information Module* ........ ២២

*Figure 26: FIN Certificate* ........ ២២

*Figure 27: e-Filing System Dashboard – Submitting FS Module* ........ ២៣

*Figure 28: Submitting FS – Choosing Entity Type* ........ ២៤

*Figure 29: Submitting FS – Income Form* ........ ២៤

*Figure 30: Submitting FS – Expenses Form* ........ ២៥

*Figure 31: Submitting FS – Profit or Loss Form* ........ ២៦

*Figure 32: Submitting FS – Assets Form* ........ ២៧

*Figure 33: Submitting FS – Liabilities Form* ........ ២៨

*Figure 34: Submitting FS – Equity Form* ........ ២៩

*Figure 35: Submitting FS – Submit Form* ........ ៣០

*Figure 36: Submitting FS – Pending Upload Document* ........ ៣១

*Figure 37: Submitting FS – Upload Document Form* ........ ៣១

*Figure 38: Pending Payment* ........ ៣២

*Figure 39: Payment Options Form* ........ ៣៣

*Figure 40: Payment Option – ACLEDA* ........ ៣៤

*Figure 41: e-Filing System – Receipt* ........ ៣៥

# អក្សរកាត់

| ល.រ | អក្សរកាត់ | អក្សរពេញ |
|---|---|---|
| ១ | ស.ហ | សហគ្រាស |
| ២ | ន.គ.ស | និយ័តករគណនេយ្យនិងសវនកម្ម |
| ៣ | អ.រ.ហ | លេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុ |
| ៤ | FIN | Financial Reporting Identification Number |
| ៥ | FS | Financial Statements |
| ៦ | ICT | Information and Communication Technology |

# ពាក្យបច្ចេកទេស

| ល.រ | ភាសាខ្មែរ | English |
|---|---|---|
| ១ | ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុ | e-Filing System |
| ២ | ការស្នើសុំលេខអត្តសញ្ញាណកម្ម | Requesting FIN |
| ៣ | ការដាក់របាយការណ៍ហិរញ្ញវត្ថុ | Submitting FS |
| ៤ | របាយការណ៍ចំណេញ- ខាត | Statement of Profit or Loss |
| ៥ | របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | Statement of Financial Position |

# ១.សេចក្តីផ្តើម

សេដ្ឋកិច្ចឌីជីថល គឺជាសេដ្ឋកិច្ចដែលពឹងផ្អែកលើការប្រើប្រាស់ប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានក្នុងការភ្ជាប់ទំនាក់ទំនងគ្នា រវាងមនុស្ស, អាជីវកម្ម, ឧបករណ៍, ទិន្នន័យ និងដំណើរការនានា។ រាជរដ្ឋាភិបាលកម្ពុជាមានបំណងប្រាថ្នាប្រែក្លាយសេដ្ឋកិច្ចតាមបែបប្រពៃណីឱ្យទៅជាសេដ្ឋកិច្ចតាមបែបឌីជីថលនាពេលអនាគត។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីកំណែទម្រង់ចាំបាច់នានា ក្នុងនោះក៏មានផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) ផងដែរ។

នៅក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ (COVID-19) ដែលបានបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គមនៅលើសកលលោករួមទាំង ព្រះរាជាណាចក្រកម្ពុជាផងដែរ។ វិធានការចំពោះមុខសម្រាប់ដោះស្រាយបញ្ហាពេលមានវិបត្តិ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) គឺពិតជាមិនអាចខ្វះបាន ក្នុងការជួយធានាប្រក្រតីភាពនៃកិច្ចការងាររបស់ស្ថាប័នរដ្ឋ និងឯកជនដែលជាផ្នែកមួយនៃជន្ទល់សេដ្ឋកិច្ចរបស់ប្រទេស។

ក្រោមការចង្អុលបង្ហាញផ្ទាល់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និងជា **ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** និយ័តករគណនេយ្យនិងសវនកម្ម ដែលមានបេសកកម្មគ្រប់គ្រងនិងអភិវឌ្ឍវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម បានអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការផ្តល់សេវាសាធារណៈនានា និងបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ រួមទាំងប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសផងដែរ (e-Filing System) ។

# ២.គោលបំណង

ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីជួយសម្រួលដល់កិច្ចដំណើរការនៃការដាក់ ត្រួតពិនិត្យ និងរក្សាទុករបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ប្រព័ន្ធនេះនឹងរួមចំណែកកាត់បន្ថយចំណាយរបស់សហគ្រាស ក្នុងការបំពេញកាតព្វកិច្ចនានាចំពោះរដ្ឋ បង្កើនតម្លាភាព ធានាគណនេយ្យភាព និងភាពស្អាតស្អំ ព្រមទាំងលើកកម្ពស់គុណភាពនៃសេវាសាធារណៈផងដែរ។

# ៣.អំពីប្រព័ន្ធ

## ៣.១ ទិដ្ឋភាពរួម

e-Filing System មានមុខងារធំៗចំនួន០២ (ពីរ) គឺ÷

១. មុខងារស្នើសុំលេខអត្តសញ្ញាណកម្ម (Requesting FIN Module)

២. មុខងារដាក់របាយការណ៍ហិរញ្ញវត្ថុ (Submitting FS Module)




*Figure 1: Overview of e-Filing System*

## ៣.២ នីតិវិធីអនុវត្ត

ខាងក្រោមនេះ គឺជាដ្យាក្រាម (Diagram) ដែលបង្ហាញអំពីទិដ្ឋភាពរួមនៃដំណើរការរបស់មុខងារធំៗទាំង ០២ របស់ប្រព័ន្ធ។ ចំណែកឯការណែនាំអំពីរបៀបអនុវត្តនឹងមានពន្យល់លម្អិតក្នុងចំណុចទី៤ខាងក្រោម។

### ៣.២.១ មុខងារស្នើសុំលេខអត្តសញ្ញាណកម្ម




*Figure 2: Overview of Requesting FIN Module*

### ៣.២.២ មុខងារដាក់របាយការណ៍ហិរញ្ញវត្ថុ




*Figure 3: Overview of Submitting FS Module*

# ៤.លំហូរការងារ និងរបៀបអនុវត្ត

## ៤.១ ការគ្រប់គ្រងគណនី

### ៤.១.១ របៀបបង្កើតគណនី

សហគ្រាសត្រូវមាន email ផ្លូវការមួយដើម្បីធ្វើការបង្កើតគណនីជាមួយប្រព័ន្ធ e-Filing សម្រាប់ប្រើប្រាស់ក្នុងការស្នើសុំលេខអត្តសញ្ញាណកម្ម និងការដាក់របាយការណ៍ហិរញ្ញវត្ថុ។ សូមធ្វើតាមជំហានដូចខាងក្រោម÷

- **ជំហានទី១÷** សូមចូលទៅកាន់គេហទំព័ររបស់ ន.គ.ស តាមរយៈតំណភ្ជាប់ www.acar.gov.kh បន្ទាប់មកនៅក្នុងផ្នែក សេវាកម្មអេឡិចត្រូនិច សូមចុចលើពាក្យ **"ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស"** ឬតាមរយៈតំណភ្ជាប់ efiling.acar.gov.kh ។



Figure 4: ACAR Website

- **ជំហានទី២៖** នៅខាងលើផ្នែកខាងស្តាំនៃប្រព័ន្ធ e-Filing សូមចុចលើពាក្យ "ចុះឈ្មោះ"។



Figure 5: Authentication Page

- **ជំហានទី៣÷** ធ្វើការបំពេញព័ត៌មានក្នុងប្រអប់ដូចរូបភាពខាងក្រោម រួចចុចប៊ូតុង “ចុះឈ្មោះ”។




*Figure 6: Create Account Form*

- **ជំហានទី៤÷** ប្រព័ន្ធនឹងធ្វើការផ្ញើតំណភ្ជាប់ សម្រាប់កំណត់ពាក្យសម្ងាត់ទៅកាន់ email របស់អ្នក។ ករណីមិនទទួលបាន email សូមចុចប៊ូតុង “បញ្ជូនសារម្តងទៀត”។




*Figure 7: Resend Email Form*

- **ជំហានទី៥÷** សូមធ្វើការពិនិត្យប្រអប់សារ (email) របស់អ្នក រួចចុចប៊ូតុង "កំណត់ពាក្យសម្ងាត់"។




*Figure 8: Set Password Email*

- **ជំហានទី៦÷** កំណត់ពាក្យសម្ងាត់ រួចសូមចុចប៊ូតុង "បញ្ជូន"។




*Figure 9: Set Password Form*

## ៤.១.២ របៀបចូលប្រើប្រាស់ប្រព័ន្ធ

បន្ទាប់ពីបង្កើតគណនីរួចរាល់ សហគ្រាសអាចចូលប្រើប្រាស់ប្រព័ន្ធបានដោយធ្វើការបំពេញព័ត៌មានក្នុងប្រអប់ email និង ពាក្យសម្ងាត់ រួចចុចប៊ូតុង "ចូលប្រើប្រព័ន្ធ" ។




*Figure 10: Log in Form*

## ៤.១.៣ របៀបផ្លាស់ប្តូរពាក្យសម្ងាត់

- **ជំហានទី១÷** នៅលើទំព័រចូលប្រើប្រាស់ប្រព័ន្ធ ផ្នែកខាងឆ្វេងប៊ូតុងចូលប្រើប្រាស់ប្រព័ន្ធ សូមចុចលើពាក្យ "ភ្លេចពាក្យសម្ងាត់?" ។




*Figure 11: Reset Password Link*

- **ជំហានទី២÷** សូមបញ្ចូល email រួចចុចប៊ូតុង “បញ្ជូន” ។




*Figure 12: Resend Email Form*

- **ជំហានទី៣÷** សូមធ្វើការពិនិត្យប្រអប់សារ (email) របស់អ្នក រួចចុចប៊ូតុង “កំណត់ពាក្យសម្ងាត់” ។




*Figure 13: Reset Password Email*

- **ជំហានទី៤÷** កំណត់ពាក្យសម្ងាត់ថ្មីរបស់អ្នក រួចចុចប៊ូតុង "បញ្ជូន"។




*Figure 14: Reset Password Form*

## ៤.២ ការដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណកម្ម

### ៤.២.១ របៀបស្នើសុំលេខអត្តសញ្ញាណកម្ម

លេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុ (FIN) គឺជាលេខសម្គាល់សហគ្រាសនីមួយៗសម្រាប់ប្រើប្រាស់ក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុ តាមប្រព័ន្ធ e-Filing របស់ ន.គ.ស។ ដើម្បីទទួលបានលេខអត្តសញ្ញាណកម្មសូមអនុវត្តដូចខាងក្រោម÷

- **ជំហានទី១÷** នៅទំព័រដើមរបស់ប្រព័ន្ធ (Dashboard) សូមចុចលើពាក្យ "ស្នើសុំលេខអត្តសញ្ញាណកម្ម"។




*Figure 15: e-Filing System Dashboard – Requesting FIN Module*

- **ជំហានទី២÷** សូមជ្រើសរើសប្រភេទសហគ្រាស “រង ឬ មិនរងសវនកម្មឯករាជ្យ” ។




*Figure 16: Requesting FIN – Choosing Entity Type*

- **ជំហានទី៣÷** សូមធ្វើការបំពេញព័ត៌មានទូទៅរបស់សហគ្រាស រួចចុចប៊ូតុង "រក្សាទុកបណ្ដោះអាសន្ន" រួចចុចប៊ូតុង "បន្ទាប់" ។




*Figure 17: Requesting FIN – General Information Form*

- **ជំហានទី៤÷** សូមធ្វើការបំពេញអាស័យដ្ឋានសហគ្រាស រួចចុចប៊ូតុង "រក្សាទុកបណ្ដោះអាសន្ន" រួចចុចប៊ូតុង "បន្ទាប់" ។




*Figure 18: Requesting FIN – Address Information Form*

- **ជំហានទី៥÷** សូមធ្វើការបំពេញព័ត៌មានហិរញ្ញវត្ថុ រួចចុចប៊ូតុង "រក្សាទុកបណ្តោះអាសន្ន" រួចចុចប៊ូតុង "បន្ទាប់" ។




*Figure 19: Requesting FIN – Financial Information Form*

- **ជំហានទី៦ (សម្រាប់តែសហគ្រាសរងសវនកម្មឯករាជ្យ)÷** សូមធ្វើការបំពេញព័ត៌មានសវនកម្ម រួចចុចប៊ូតុង "រក្សាទុកបណ្តោះអាសន្ន" រួចចុចប៊ូតុង "បន្ទាប់" ។




*Figure 20: Requesting FIN – Audit Information Form*

- **ជំហានទី៧÷** សូមធ្វើការដាក់ភ្ជាប់ឯកសារពាក់ព័ន្ធដែលតម្រូវ រួចចុចប៊ូតុង "រក្សាទុកបណ្តោះអាសន្ន" រួចចុចប៊ូតុង "បញ្ជូនពាក្យស្នើសុំ" ។




*Figure 21: Requesting FIN – Uploading Documents Form*

- **ជំហានទី៨÷** ផ្ទៀងផ្ទាត់និងបញ្ជាក់ព័ត៌មានរួចចុចប៊ូតុង "បញ្ជូន" ។




*Figure 22: Requesting FIN – Confirm Information Form*

- **ជំហានទី៩÷** សូមចុចប៊ូតុង "យល់ព្រម" ដើម្បីដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណកម្ម។



*Figure 23: Requesting FIN – Submit Form*

**សំគាល់÷** សហគ្រាសត្រូវធ្វើការរងចាំក្រុមការងារ ន.គ.ស. ធ្វើការត្រួតពិនិត្យពាក្យស្នើសុំ និងអនុម័តផ្តល់លេខអត្តសញ្ញាណកម្មជូនក្នុងចន្លោះពេល១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ។ ន.គ.ស. នឹងធ្វើការជូនដំណឹងតាមរយៈសារអេឡិចត្រូនិច (email) ។



ព័ត៌មានទូទៅ | ព័ត៌មានហិរញ្ញវត្ថុ | ឯកសារ

ពាក្យស្នើសុំរបស់លោកអ្នកត្រូវបានបញ្ជូនរួចរាល់

សូមមេត្តារង់ចាំ រយៈពេលនៃការត្រួតពិនិត្យមានចំនួន ១០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានបញ្ជូនពាក្យស្នើសុំ។

| | |
|---|---|
| ឈ្មោះសហគ្រាស | ក្រុមហ៊ុន អេ ប៊ី ស៊ី |
| ឈ្មោះសហគ្រាសជាអក្សរឡាតាំង | A B C Company |
| អាសយដ្ឋាន | ផ្ទះលេខ/អគារ: ABC Building ផ្លូវលេខ: 355 ភូមិ/ក្រុម: 12, ឃុំ/សង្កាត់: Phnom Penh, ស្រុក/ខណ្ឌ: ទួលគោក, ខេត្ត/រាជធានី: Phnom Penh |
| លេខទូរស័ព្ទសហគ្រាស | 081644663 |
| សារអេឡិចត្រូនិក | yeanpholla.rupp@gmail.com |
| សកម្មភាពអាជីវកម្មចម្បង | ធ្វើពាណិជ្ជកម្ម |
| សកម្មភាពអាជីវកម្មបន្ទាប់បន្សំ | |
| ចំនួននិយោជិតសរុប | 100 |
| កាលបរិច្ឆេទបង្កើតសហគ្រាស | 29-06-2021 |
| កាលបរិច្ឆេទដំណើរការអាជីវកម្មដំបូង | 29-06-2021 |
| លេខអត្តសញ្ញាណកម្មសារពើពន្ធ | TIN-0019283231 |

*Figure 24: Requesting FIN – Pending Approval Form*

## ៤.២.២ របៀបពិនិត្យមើលលេខអត្តសញ្ញាណកម្ម

ដើម្បីពិនិត្យមើលលេខអត្តសញ្ញាណកម្មដែលបានស្នើសុំ នៅលើទំព័រដើមរបស់ប្រព័ន្ធ (Dashboard) សូមចុចលើពាក្យ "លេខអត្តសញ្ញាណកម្ម" បន្ទាប់មកប្រព័ន្ធ នឹងធ្វើការបង្ហាញផ្ទាំង "វិញ្ញាបនបត្រលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស"។ សហគ្រាសអាចធ្វើការបោះពុម្ពបានដោយចុចប៊ូតុង "បោះពុម្ព"។




*Figure 25: e-Filing System Dashboard –FIN Information Module*




*Figure 26: FIN Certificate*

## ៤.៣ ការដាក់របាយការណ៍ហិរញ្ញវត្ថុ

### ៤.៣.១ របៀបដាក់របាយការណ៍ហិរញ្ញវត្ថុ

ដើម្បីអាចធ្វើការដាក់របាយការណ៍ហិរញ្ញវត្ថុបាន សហគ្រាសចាំបាច់ត្រូវទទួលបានលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុ (FIN) ពីនិយ័តករគណនេយ្យនិងសវនកម្មជាមុនសិន។ ដើម្បីដាក់របាយការណ៍ហិរញ្ញវត្ថុសូមអនុវត្តដូចខាងក្រោម÷

- **ជំហានទី១÷** នៅទំព័រដើមរបស់ប្រព័ន្ធ (Dashboard) សូមចុចលើពាក្យ "បញ្ជីរបាយការណ៍ហិរញ្ញវត្ថុ"។




*Figure 27: e-Filing System Dashboard –Submitting FS Module*

- **ជំហានទី២៖** សូមធ្វើការជ្រើសរើសប្រភេទសហគ្រាស។



Figure 28: Submitting FS – Choosing Entity Type

- **ជំហានទី៣៖** សូមបំពេញព័ត៌មានចំណូល (Income) រួចចុចប៊ូតុង "រក្សាទុកបណ្តោះអាសន្ន" រួចចុចប៊ូតុង "បន្ទាប់"។




Figure 29: Submitting FS – Income Form

- **ជំហានទី៤÷** សូមបំពេញព័ត៌មានចំណាយ (Expenses) រួចចុចប៊ូតុង “រក្សាទុកបណ្ដោះអាសន្ន” រួចចុចប៊ូតុង “បន្ទាប់” ។




*Figure 30: Submitting FS – Expenses Form*

- **ជំហានទី៥៖** ធ្វើការផ្ទៀងផ្ទាត់ព័ត៌មាន របាយការណ៍ចំណេញ-ខាត (Statement of Profit or Loss) រួចសូមធ្វើការចុចប៊ូតុង "រក្សាទុកបណ្តោះអាសន្ន" រួចនៅផ្នែកខាងលើសូមចុចពាក្យ "របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (Statement of Financial Position)"។




| លេខកូដ / Code | ឈ្មោះគណនី / Item name | ចំនួនទឹកប្រាក់ / Amount រៀល / KHR |
|---|---|---|
| R-01 | ចំណូលការប្រាក់ / Interest income | - |
| X-01 | ចំណាយការប្រាក់ / Interest expense | - |
| | **ចំណូលការប្រាក់-សុទ្ធ / Net interest income** | - |
| R-02 | ចំណូលកម្រៃ និងជើងសា / Fee and commission income | 6,262.00 |
| X-02 | ចំណាយកម្រៃ និងជើងសា / Fee and commission expense | - |
| | **ចំណូលកម្រៃ និងជើងសា - សុទ្ធ / Net Fee and commission income** | **6,262.00** |
| X-03 | សំវិធានធនសម្រាប់ការខាតពីការធ្លាក់ចុះតម្លៃរបស់ឥណទាននិងបុរេប្រទាន, ប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងគណនីត្រូវទទួលផ្សេងទៀត / Allowances for impairment losses on loan and advances, deposits and placements with other banks and other receivables | - |
| | **ចំណេញសុទ្ធក្រោយសំវិធានធនសម្រាប់ការធ្លាក់ចុះតម្លៃ / Net income after allowance for impairment** | **6,262.00** |
| R-97 | ចំណូលផ្សេងទៀត / Other income | 31,313.00 |
| X-97 | ចំណាយផ្សេងទៀត / Other Expenses | - |
| | **ប្រាក់ចំណេញ-ខាតមុនបង់ពន្ធ / Profit-Loss before tax** | **37,575.00** |
| X-98 | ចំណាយពន្ធលើប្រាក់ចំណេញ / Income Tax Expense | - |
| | **ប្រាក់ចំណេញ-ខាតប្រចាំឆ្នាំ / Profit-Loss for the year** | **37,575.00** |

*Figure 31: Submitting FS – Profit or Loss Form*

- **ជំហានទី៦៖** បំពេញព័ត៌មានទ្រព្យសកម្ម (Assets) រួចចុចប៊ូតុង "រក្សាទុកបណ្ដោះអាសន្ន" រួចចុចប៊ូតុង "បន្ទាប់" ។




*Figure 32: Submitting FS – Assets Form*

- **ជំហានទី៧៖** សូមបំពេញព័ត៌មានបំណុល (Liabilities) រួចចុចប៊ូតុង "រក្សាទុកបណ្ដោះអាសន្ន" រួចចុចប៊ូតុង "បន្ទាប់"។



របាយការណ៍ចំណេញ-ខាត
Statement of Profit or Loss
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020
For the year ended 31 December 2020

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
Statement of financial position
គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2020
As at 31 December 2020

លេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុ A-21-00008

ទ្រព្យសកម្ម Assets | បំណុល Liabilities | មូលធន Equity

| លេខកូដ / Code | ឈ្មោះគណនី / Item name | ចំនួនទឹកប្រាក់ / Amount<br>រៀល / KHR |
|---|---|---|
| L-01 | ប្រាក់បញ្ញើរបស់ធនាគារ និង ស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត / Deposits of other banks and financial institutions | 0 |
| L-02 | ប្រាក់បញ្ញើទទួលពីអតិថិជន / Deposits from customers | 0 |
| L-03 | ការខ្ចី / Borrowings | 0 |
| L-04 | បំណុលបន្ទាប់បន្សំ / Subodinated debts | 0 |
| L-05 | ពន្ធលើប្រាក់ចំណូលត្រូវបង់ / Income tax payables | 0 |
| L-06 | បំណុលភតិសន្យា / Leased liabilities | 0 |
| L-07 | អត្ថប្រយោជន៍និយោជិតត្រូវសង / Employee benefit payables | 0 |
| L-08 | បំណុលពន្ធពន្យារ-សុទ្ធ / Deferred tax liabilities, net | 0 |
| L-97 | បំណុលផ្សេងៗ / Other liabilities | 0 |
| L-99 | **បំណុលសរុប / Total liabilities** | **0** |

ទ្រព្យសកម្មសរុប / Total Assets 0 KHR
បំណុលនិងមូលធនសរុប / Total Liabilities and equity 37,575 KHR

< ថយក្រោយ
រក្សាទុកបណ្ដោះអាសន្ន
បន្ទាប់ >

*Figure 33: Submitting FS – Liabilities Form*

- **ជំហានទី៨÷** សូមបំពេញព័ត៌មានមូលធន (Equity) រួចចុចប៊ូតុង "រក្សាទុកបណ្ដោះអាសន្ន" រួចចុចប៊ូតុង "បញ្ជូន"។

  **សម្គាល់÷** ទ្រព្យសកម្មសរុប (Total Assets) ត្រូវសមតុល្យទៅនឹងបំណុល និងមូលធនសរុប (Total Liabilities and Equity)។




*Figure 34: Submitting FS – Equity Form*

- **ជំហានទី៩÷** ផ្ទៀងផ្ទាត់ និងបញ្ជាក់ព័ត៌មានរួចចុចប៊ូតុង“បញ្ជូន” ។



សូមផ្ទៀងផ្ទាត់ឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុរបស់លោកអ្នក

របាយការណ៍ចំណេញ-ខាត
Statement of Profit or Loss

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
Statement of financial position

**និយ័តករគណនេយ្យនិងសវនកម្ម / ACAR**

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ / Statement of financial position**

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2020
As at 31 December 2020

**ទ្រព្យសកម្ម / Assets**

| | | រៀល / KHR |
|---|---|---|
| A-01 | សាច់ប្រាក់ក្នុងដៃ / Cash on hand | 37,575.00 |
| A-02 | ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា / Deposits at NBC | - |
| A-03 | ប្រាក់បញ្ញើនៅធនាគារផ្សេងទៀត / Deposits at other banks | - |
| A-04 | ការវិនិយោគហិរញ្ញវត្ថុ / Financial investments | - |
| A-05 | ការវិនិយោគក្នុងក្រុមហ៊ុនសម្ព័ន្ធ / Investments in associates | - |
| A-06 | ការវិនិយោគក្នុងក្រុមហ៊ុនបណ្តាក់ទុនរួម / Investments in Joint Ventures | - |
| A-07 | កម្ចីនិងប្រាក់បុរេប្រទាន - សុទ្ធ / Loans and advance, net | - |
| A-08 | ប្រាក់តម្កល់តាមច្បាប់ / Statutory Deposits | - |
| A-09 | ទ្រព្យ និងបរិក្ខារ / Property and Equipment | - |
| A-10 | ទ្រព្យអរូបី / Intangible assets | - |
| A-11 | សិទ្ធិនៃការប្រើប្រាស់ទ្រព្យ / Right-of-Use assets | - |
| A-12 | ទ្រព្យសកម្មពន្ធពន្យារ- សុទ្ធ / Deferred tax assets, net | - |
| A-97 | ទ្រព្យសកម្មផ្សេងទៀត / Other assets | - |
| **A-99** | **ទ្រព្យសកម្មសរុប / Total assets** | **37,575.00** |

**បំណុល / Liabilities**

| | | រៀល / KHR |
|---|---|---|
| L-01 | ប្រាក់បញ្ញើរបស់ធនាគារ និង ស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត / Deposits of other banks and financial institutions | - |
| L-02 | ប្រាក់បញ្ញើទទួលពីអតិថិជន / Deposits from customers | - |
| L-03 | ការខ្ចី / Borrowings | - |
| L-04 | បំណុលបន្ទាប់បន្សំ / Subodinated debts | - |
| L-05 | ពន្ធលើប្រាក់ចំណូលត្រូវបង់ / Income tax payables | - |
| L-06 | បំណុលភតិសន្យា / Leased liabilities | - |
| L-07 | អត្ថប្រយោជន៍និយោជិតត្រូវសង / Employee benefit payables | - |
| L-08 | បំណុលពន្ធពន្យារ- សុទ្ធ / Deferred tax liabilities, net | - |
| L-97 | បំណុលផ្សេងៗ / Other liabilities | - |
| **L-99** | **បំណុលសរុប / Total liabilities** | **-** |

**មូលធន / Equity**

| | | រៀល / KHR |
|---|---|---|
| EQ-1.9 | ដើមទុនជាភាគហ៊ុនចុងគ្រា / Ending share capital | - |
| EQ-2.9 | បុព្វលាភជាភាគហ៊ុនចុងគ្រា / Ending share premium | - |
| EQ-3.9 | ប្រាក់ចំណេញរក្សាទុកចុងគ្រា / Ending retained earnigs | 37,575.00 |
| EQ-4.9 | គណនីបម្រុងចុងគ្រា / Ending Reserve Accounts | - |
| | មូលធនសរុប / Total Equity | 37,575.00 |
| | បំណុលនិងមូលធនសរុប / Total Liabilities and equity | 37,575.00 |

ខ្ញុំសូមធានាអះអាង និង ទទួលខុសត្រូវចំពោះមុខច្បាប់ថាព័ត៌មានដែលបំពេញខាងលើនេះ ពិតជាត្រឹមត្រូវប្រាកដមែន ✓ បញ្ជូន បោះបង់

2021 © និយ័តករគណនេយ្យនិងសវនកម្ម    របៀបប្រើប្រាស់    អំពីយើង

*Figure 35: Submitting FS – Submit Form*

- **ជំហានទី១០÷** សូមធ្វើការដាក់ឯកសារ របាយការណ៍ហិរញ្ញវត្ថុ (FS) ដោយចុចលើប៊ូតុង "បញ្ជូនឯកសារ"។




*Figure 36: Submitting FS – Pending Upload Document*

- **ជំហានទី១១÷** ជ្រើសរើសឯកសារ រួចចុចប៊ូតុង "បញ្ជូន"។




*Figure 37: Submitting FS – Upload Document Form*

## ៤.៣.២ ការបង់ថ្លៃសេវាកម្មទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុ

- **ជំហានទី១÷** សូមចុចលើប៊ូតុង "វិក្កយបត្រ" ។




*Figure 38: Pending Payment Form*

- **ជំហានទី២÷** សូមជ្រើសរើសធនាគាររួចចុចប៊ូតុង "បង់ប្រាក់" ។

**សម្គាល់÷** ប្រសិនបើមានបញ្ហាក្នុងការបង់ប្រាក់តាមប្រព័ន្ធអនឡាញ សហគ្រាសអាចធ្វើការ បោះពុម្ពវិក្កយបត្រ និងអាចធ្វើការបង់ប្រាក់នៅបញ្ជរធនាគារដៃគូរដោយផ្ទាល់បាន ។

- **ឈ្មោះធនាគារ÷** អេស៊ីលីដា (០០០១-០៤-០៩៤៥៨០-១-៨)
- **ឈ្មោះគណនី÷** និយ័តករគណនេយ្យនិងសវនកម្ម




*Figure 39: Payment Options Form*

- **ជំហានទី៣(ធនាគារអេស៊ីលីដា)÷** សូមបញ្ចូលលេខទូរស័ព្ទ ឬលេខគណនីធនាគារអេស៊ីលីដារបស់អ្នក រួចចុចប៊ូតុង “Validate” ប្រព័ន្ធនឹងធ្វើការផ្ញើរលេខកូដ OTP ទៅកាន់លេខទូរស័ព្ទអ្នក សូមបញ្ចូលលេខកូដ OTP រួចចុចប៊ូតុង “Verify” ។




*Figure 40: Payment Options – ACLEDA*

- **ជំហានទី៤÷** ប្រព័ន្ធនឹងបង្ហាញបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ ។

**បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់**

ទំព័រដើម • វិក្កយបត្របង់ចំណូល

បោះបង់ | បោះពុម្ពបង្កាន់ដៃ

**និយ័តករគណនេយ្យនិងសវនកម្ម**

**បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់**

កាលបរិច្ឆេទ ÷ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១
លេខបង្កាន់ដៃ ÷ R2019-00001
ឈ្មោះសហគ្រាស ÷ និយតករគណនេយ្យនិងសវនកម្ម
លេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុ (អ.រ.ហ.) ÷ **A-21-00008**

| ល.រ | លេខកូដសេវា | លេខវិក្កយបត្រ | មាតិកាចំណូល | ចំនួនទឹកប្រាក់បានបង់ | ធនាគារអេស៊ីលីដា |
|---|---|---|---|---|---|
| 1 | 105010005 | 2019-00004 | សេវាកម្មទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចដោយសហគ្រាស | 300,000 | 0001-04-094580-1-8 |
| សរុប | | | | 300,000 | |

ហត្ថលេខា

បានឃើញ និងឯកភាព
**អគ្គនាយក**

*Figure 41: e-Filing System – Receipt*

# ទំនាក់ទំនង

**១. ផ្នែកបច្ចេកវិទ្យាព័ត៌មាន**

| | | |
|---|---|---|
| លោក ជីវ ហ៊ | ០១០ ៣០៤ ៤៧០ | c.hor@acar.gov.kh |
| លោក យាន ផល្លា | ០៨១ ៦៤៤ ៦៦៣ | y.pholla@acar.gov.kh |

**២. ផ្នែកបំពេញព័ត៌មានហិរញ្ញវត្ថុ**

| | | |
|---|---|---|
| លោក យ៉ាង ជីងលីង | ០៨៨ ៧០៧ ១០៧០ | y.jingling@acar.gov.kh |

**៣. ផ្នែកអនុលោមភាព**

| | | |
|---|---|---|
| លោក លី កុសល | ០១០ ៣០៩ ២០០ | l.kosal@acar.gov.kh |

ថ្ងៃអង្គារ ១២រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០២១

**អគ្គនាយក**

**ប៊ុ ថារិន**